ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពុទ្ធមណ្ឌលវិបស្សនាធុរៈ
នៃព្រះរាជាណាចក្រកម្ពុជា

# ធម្មាទាសកថា

ព្រះចាប្បាត់ឧត្តមលិខិត **សុខ-ស៊ីវ** វត្តលង្កា ភ្នំពេញ ទេសនាជាក់វិទ្យុជាតិកម្ពុជា កាលពីថ្ងៃ ៨ កើត ខែជេស្ឋ ឆ្នាំជូតសំរិទ្ធិស័ក ព. ស. ២៤៩១ (០៤ មិថុនា ១៩៤៩)

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

វេលានេះ អាត្មាភាពសូមសំដែងនូវធម្មបរិយាយឈ្មោះ **ធម្មាទាសៈ "ធម៌ដូចកែវឆ្លុះ"** ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែង មាននៅក្នុង**សុត្តន្តបិដក គម្ពីរទីឃនិកាយ មហាវគ្គ** ជាធម្មស្សវនាការ ដូចតទៅនេះ ។

ធម្មបរិយាយឈ្មោះ ធម្មាទាសៈ នេះមាន ៤ យ៉ាងគឺ:

| | |
|---|---|
| **១- ពុទ្ធេ អវេច្ចប្បសាទោ** | សេចក្ដីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះពុទ្ធ ។ |
| **២- ធម្មេ អវេច្ចប្បសាទោ** | សេចក្ដីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះធម៌ ។ |
| **៣- សង្ឃេ អវេច្ចប្បសាទោ** | សេចក្ដីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះសង្ឃ ។ |
| **៤- អរិយកន្តសីលំ** | សីលជាទីគាប់ចិត្តរបស់អរិយបុគ្គល ។ |

ធម៌ទាំង ៤ យ៉ាងនេះតែងមានក្នុងអរិយបុគ្គល, ជាធម៌ជាន់ខ្ពស់ដូចជាគ្រឿងសំរាប់ឆ្លុះមើលគតិ និង បរលោក របស់ខ្លួន និង បុគ្គលដទៃឬថាសំរាប់ឆ្លុះមើលនូវចុតិ និង បដិសន្ធិក៏ បាន ។ អធិប្បាយតាមពិត ធម្មាទាសកថានេះ ព្រះសក្យមុនីសម្ពុទ្ធទ្រង់សំដែងក្នុង**មហាបរិនិព្វានសូត្រ** ចំពោះព្រះអានន្ទដ៏មានអាយុថា: "ម្នាលអានន្ទ ! សត្វគឺមនុស្សដែលធ្វើមរណកាលដោយហេតុណា ហេតុនោះមិនជាអស្ចារ្យទេ ព្រោះកាលបើមនុស្សនោះៗធ្វើមរណកាលហើយ អ្នកទាំងឡាយមុខជានឹងមករកតថាគត ហើយសួរនូវដំណើរនោះ ។ ម្នាលអានន្ទ ! នេះជាសេចក្ដីលំបាកដល់តថាគតណាស់" ។

ហើយទ្រង់សំដែងតទៅទៀតថា "ម្នាលអានន្ទ ! ព្រោះហេតុនោះ អរិយសាវ័កប្រកបដោយធម្មចរិយាណា កាលបើប្រាថ្នានឹងព្យាករ ក៏គប្បីព្យាករខ្លួនដោយខ្លួនឯងបានថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់អបាយទុគ្គតិវិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល លែងធ្លាក់ចុះហើយ ជាបុគ្គលទៀងមានសេចក្ដីត្រាស់ដឹងទៅខាងមុខ ។ ដូច្នេះ តថាគតនឹងសំដែងនូវធម្មបរិយាយនោះឈ្មោះ ធម្មាទាសៈ (ធម៌ដូចជាកែវឆ្លុះ) ។

## ធម្មបរិយាយទី ១

ព្រះសម្ពុទ្ធបរមគ្រូទ្រង់សំដែងថា: អរិយសាវ័កប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះពុទ្ធ

ថា: **ឥតិបិសោ ភគវា អរហំ** ព្រះមានព្រះភាគអង្គនោះទ្រង់ឆ្ងាយចាកកិលេសហើយ **សម្មាសម្ពុទ្ធោ**ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯងដោយប្រពៃ **វិជ្ជាចរណសម្បន្នោ** ទ្រង់បរិបូណ៌ដោយវិជ្ជានឹងចរណៈ **សុគតោ** ទ្រង់ ដល់នូវសុន្ទរស្ថាន **លោកវិទូ** ទ្រង់ជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ប្រសើរដោយសីលាទិគុណ **បុរិសទម្មសារថិ** ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានបាន **សត្ថា ទេវមនុស្សានំ** ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ត្រាស់ដឹងនូវអរិយសច្ចធម៌ **ភគវា** ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ ព្រះអរិយបុគ្គលទាំងឡាយមានមនោសញ្ចេតនាជ្រះថ្លាចំពោះព្រះពុទ្ធគុណ ទាំង ១០ នេះ ពុំមានរំភើបញាប់ញ័រឡើយ ។ នេះជាធម្មាទាសៈទី ១ ។

ឯព្រះពុទ្ធគុណទាំង ១០ នេះ បើបំព្រួញឲ្យខ្លីមកនៅត្រឹមតែ ៣ គឺ ៖

១- **បញ្ញាគុណ** សំដៅយកការត្រាស់ដឹងនូវមគ្គញ្ញាណ ដែលជាទីតាំងនៃសព្វញ្ញុតញ្ញាណ និងញាណដ៏សេស មានចតុវេសារជ្ជញ្ញាណ, ទសពលញ្ញាណ និង អនាវរញ្ញាណ ជាដើម ដែលជាហេតុឲ្យសម្រេចគុណដល់សព្វសត្វ ។

២- **វិសុទ្ធិគុណ** សំដៅយកសេចក្តីបរិសុទ្ធរបស់ព្រះអង្គ បានដល់ការលះបង់នូវកិលេសព្រមទាំងវាសនាដាច់ស្រឡះ ទោះបីលោកធម៌ទាំង ៨ ប្រការកើតឡើងចំពោះព្រះអង្គ ក៏ទឹកព្រះទ័យរបស់ព្រះអង្គមិនញាប់ញ័រឡើយ ។

៣- **ករុណាគុណ** បានដល់សេចក្តីអាណិតអាសូរដល់ពួកសត្វដែលកំពុងក្តៅក្រហល់ក្រហាយអន្ទះអន្ទែងដោយភ្លើងទុក្ខ ភ្លើងកិលេស ជ្រមុជឈ្លក់នៅក្នុងសមុទ្រគឺ សង្សារ រងទុក្ខវេទនា រកទីបំផុតគ្មាន ។ ទ្រង់មានព្រះទ័យប្រាថ្នានឹងស្រោចស្រង់ លើកស្ទួយសត្វទាំងនោះឲ្យរួចអំពីទុក្ខវេទនានោះ ។

គុណទាំងបីនេះ ជាទីប្រជុំចុះនៃគុណទាំង ១០ គឺ ៖

១- សម្មាសម្ពុទ្ធោ,

២- វិជ្ជាចរណសម្បន្នោ,

៣- លោកវិទូ ។ (បីនេះសង្គ្រោះចូលក្នុងបញ្ញាគុណ) ។

៤- អរហំ,

៥- សុគតោ,

៦- អនុត្តរោ ។ (បីនេះសង្គ្រោះចូលក្នុងវិសុទ្ធិគុណ) ។

៧- បុរិសទមមសារថិ,

៨- សត្ថាទេវមនុស្សានំ,

៩- ពុទ្ធោ,

១០- ភគវា ។ (បួននេះសង្គ្រោះចូលក្នុងករុណាគុណ) ។

ម្យ៉ាងទៀតគុណទាំងបីនេះ បើបំព្រួញឲ្យខ្លីមកទៀតនៅត្រឹមតែពីរ គឺ **អត្តហិតគុណ ១, បរហិតគុណ ១** ។

គុណទាំងពីរនេះជាទីប្រជុំចុះនៃគុណទាំង ១០ គឺ អរហំ ១, សម្មាសម្ពុទ្ធោ ១, វិជ្ជាចរណសម្បន្នោ ១, សុគតោ ១, លោកវិទូ ១, ប្រាំនេះជា**អត្តហិតគុណ** ព្រោះគុណជាប្រយោជន៍ចំពោះព្រះអង្គ ។ អនុត្តរោ ១, បុរិសទម្មសារថិ ១, សត្ថាទេវមនុស្សានំ ១, ពុទ្ធោ ១, ភគវា ១, ប្រាំនេះជា**បរហិតគុណ** ព្រោះគុណជាប្រយោជន៍ចំពោះសត្វដទៃ ។

## ធម្មបរិយាយទី ២

ព្រះសម្ពុទ្ធបរមគ្រូទ្រង់សំដែងថា អរិយសាវ័កប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ថា **ស្វាក្ខាតោ ភគវតា ធម្មោ** ធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយដោយប្រពៃ **សន្ទិដ្ឋិកោ** ធម៌ដែលអរិយបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឲ្យនូវផលមិនរង់ចាំកាល **ឯហិបស្សិកោ** ជាធម៌គួរនឹងហៅថា អ្នកចូលមកមើលដូច្នេះបាន **ឱបនយិកោ** ជាធម៌ដែលអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន **បច្ចត្តំវេទិតព្វោ វិញ្ញូហិ** ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូ បុគ្គលជាដើមគប្បីដឹងដោយជាក់ច្បាស់ក្នុងចិត្តនៃខ្លួន ។

អរិយបុគ្គលទាំងឡាយ មានមនោសញ្ចេតនាជ្រះថ្លាចំពោះព្រះធម្មគុណទាំង ៦ នេះពុំមានរំភើបញាប់ញ័រឡើយ ។ នេះជាធម្មាទាសៈទី ២ ។

ឯ**ព្រះធម្មគុណ**នេះបានដល់បិដកទាំងបី គឺៈ វិន័យបិដក ១, សុត្តន្តដក ១ អភិធម្មបិដក ១ ។

ដែលហៅថា **វិន័យបិដក** គឺកញ្ជើ ឬភាជនៈសម្រាប់ដម្កល់នូវវិភង្គទាំងពីរ គឺ ភិក្ខុវិភង្គ និងភិក្ខុនីវិភង្គ , និងខន្ធកៈទាំង ២២ មានមហាខន្ធកៈជាដើម, និងបាតិមោក្ខទាំងពីរគឺ ភិក្ខុបាតិមោក្ខនិងភិក្ខុនីបាតិមោក្ខ, ទាំងបរិវារៈ ១៦ មានកត្ថបញ្ញត្តិន្តិវារៈជាដើម ដែលព្រះថេរៈទាំងឡាយសមោធានរួបរួមក្នុងបឋមសង្គីតិ ។

ដែលហៅថា **សុត្តន្តបិដក** គឺកញ្ជើឬភាជនៈសម្រាប់ដម្កល់នូវពុទ្ធវចនៈ ដែលមាននៅក្នុងនិកាយទាំង ៥ គឺ ទីឃនិកាយ សង្គ្រោះដោយសូត្រ ៣៤ មានព្រហ្មជាលសូត្រជាដើម ១ បជ្ឈិមនិកាយ, សង្គ្រោះដោយសូត្រ ២៥២ មានមូលបរិយាយសូត្រជាដើម ១, សំយុត្តនិកាយសង្គ្រោះដោយសូត្រ ៧៧៦២ មានឱឃតរសូត្រជាដើម ១, អង្គុត្តរនិកាយសង្គ្រោះដោយសូត្រ ៩៥៥៧ មានចិត្តបរិយាទានសូត្រជាដើម ១, ខុទ្ទកនិកាយ មានប្រភេទ ១៥ មានខុទ្ទកបាឋជាដើម ១ ។

ដែលហៅថា **អភិធម្មបិដក** គឺកញ្ជើឬភាជនៈ សម្រាប់ដម្កល់នូវពុទ្ធវចនៈ ដែលមាននៅក្នុងគម្ពីរទាំង ៧ និយាយអំពីចិត្ត, ចេតសិក, រូប, និព្វាន ។

**គម្ពីរទាំង ៧ នោះ គឺ**

**១- ធម្មសង្គណី មានគំនរធម៌ចំនួន ១៣០០ (ធម្មក្ខន្ធ),**

**២- វិភង្គ មាន ៦៥០០ ធម្មខក្ខន្ធ,**

**៣- ធាតុកថាមាន ៧០០០ ធម្មក្ខន្ធ,**

**៤- បុគ្គលប្បញ្ញត្តិ មាន ៥៦០០ ធម្មក្ខន្ធ,**

**៥- កថាវត្ថុ មាន ៧១០០ ធម្មក្ខន្ធ,**

**៦- យមកៈ មាន ៥១០០ ធម្មក្ខន្ធ,**

**៧- មហាបដ្ឋាន មាន ៩៥០០ ធម្មក្ខន្ធ ។**

បិដកទាំងបីនេះ មានគំនរធម៌ចំនួន ៨៤០០០ (ព្រះធម្មក្ខន្ធ) គឺព្រះវិន័យបិដកមាន ២១០០០ ធម្មក្ខន្ធ, ព្រះសុត្តន្តបិដក មាន ២១០០០ ធម្មក្ខន្ធ, ព្រះអភិធម្មបិដក មាន ៤២០០០ ធម្មក្ខន្ធ ។

## ធម្មបរិយាយទី ៣

ព្រះសម្ពុទ្ធជាបរមគ្រូទ្រង់សំដែងថាព្រះអរិយសាវ័កប្រកបដោយ សេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះសង្ឃថាៈ **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ពួកសាវ័ករបស់ព្រះដ៏មានព្រះភាគប្រតិបត្តិដោយប្រពៃ **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ពួកសាវ័កនៃព្រះដ៏មានព្រះភាគប្រតិបត្តិដោយត្រង់ **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ពួកសាវ័ករបស់ព្រះដ៏មានព្រះភាគប្រតិបត្តិដើម្បីព្រះនិព្វាន **សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ពួកសាវ័ករបស់ព្រះដ៏មានព្រះភាគប្រតិបត្តិដោយសមគួរ **យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះ បើរាប់ជាគូនៃបុរសមាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន៨ពួកនៃសាវ័ករបស់ព្រះដ៏មានព្រះភាគនុ៎ះ, **អាហុណេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា **បាហុណេយ្យោ** លោកគួរទទួលនូវទក្ខិណាទាន **អញ្ជលិករណីយោ** ជាបុគ្គលដែលសត្វលោកគប្បីធ្វើ**អញ្ជលីកម្ម អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

អរិយបុគ្គលទាំឡាយលោកមានមនោសញ្ចេតនា ជ្រះថ្លាចំពោះព្រះសង្ឃគុណទាំង ៩ នេះ ពុំមានរំភើបញាប់ញ័រឡើយ, នេះជាធម្មាទាសៈទី ៣ ។

ឯគុណព្រះសង្ឃទាំង ៩ នេះ បើបំព្រួញចុះមកនៅត្រឹមតែពីរយ៉ាងគឺ អត្តហិតគុណ ១, បរហិតគុណ ១, ត្រង់បទថាៈ សុបដិបន្នោ ១, ឧជុបដិបន្នោ ១ ញាយបដិបន្នោ ១ សាមីចិបដិន្នោ ១ ទាំង ៤ នេះឈ្មោះថា អត្តហិតគុណ ព្រះជាគុណទំនុកបំរុងដល់ខ្លួន ។ អាហុណេយ្យោ ១, បាហុណេយ្យោ ១, ទក្ខិណេយ្យោ ១, អញ្ជលិករណីយោ ១, អនុត្តរំបុញ្ញក្ខេត្តំលោកស្ស ១, ទាំង ៥ នេះឈ្មោះថា បរហិតគុណ ព្រោះជាគុណទំនុកបំរុងដល់អ្នកដទៃ ។

## ធម្មបរិយាយទី ៤

ព្រះសម្ពុទ្ធជាបរមគ្រូទ្រង់សំដែងថាអរិយសាវ័កប្រកបដោយសីលជាទី គាប់ចិត្តរបស់អរិយៈ ជាសីលមិនដាច់, ជាសីលមិនធ្លុះ, ជាសីលមិនពពាល, ជាសីលមិនពព្រុះ, ជាសីលរបស់អ្នកជា, ជាសីលមិនជ្រោកជ្រាកដោយតណ្ហានឹងទិដ្ឋិ ជាសីលញុំាងសមាធិឲ្យប្រព្រឹត្តទៅបាន, នេះជាធម្មាទាសៈទី ៤ ។ អរិយបុគ្គលទាំងឡាយប្រកបដោយធម្មបរិយាយ ឈ្មោះធម្មាទាសៈទាំង ៤ នេះ កាលបើលោកត្រូវការឆ្លុះមើលនូវគតិនឹងបរលោករបស់បុគ្គលដទៃ នឹងខ្លួនលោកក៏អាចព្យាករបានថាៈ អាត្មាអញអស់នរកហើយ, អស់កំណើតតិរច្ឆានហើយ, អស់បេត្តិវិស័យហើយអស់អបាយទុគ្គតិវិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គលលែងធ្លាក់ចុះហើយ ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅខាងមុខ ។ សាធុរ៉ា បពិត្រសប្បុរស

ទាំងឡាយ ! បើសប្បុរសមានមនោសញ្ចេតនាប្រាថ្នានូវសេចក្តីសុខសេចក្តីចំរើន គួរខំញុំាំងសេចក្តីជ្រះថ្លាក្នុងព្រះរតនត្រៃ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ឲ្យស្ពាពរមាំមួនពុំគប្បីស្មើបរំភើបញាប់ញ័រដោយវត្ថុធាតុផ្សេងៗ ទាំងខំថែរក្សាសីលរបស់ខ្លួនឲ្យបរិសុទ្ធគត់មត់ល្អ ឲ្យជាសីលគួរដល់សេចក្តីសរសើររបស់អរិយបុគ្គលទាំងឡាយ ។

ដោយតេជៈនៃធម្មទេសនានេះ សូមទេវតាទាំងមួយហ្មឺនលោកធាតុជួយពិភត្តិរក្សាព្រះប្រិយមហាក្សត្រ ព្រមទាំងព្រះរាជវង្សានុវង្ស សូមទ្រង់ប្រសិទ្ធដោយចតុព្វិធពរ គឺៈ អាយុ, វណ្ណៈ, សុខៈ, ពលៈ បរិបូណ៌ ដោយតេជានុភាពបរិហារកម្ពុជប្រទេស ឲ្យបានលុះដល់នូវឧត្តមគតិដោយមុហុត្តកាលដ៏រួសរាន់សម័យ ! ទាំងសូមពុទ្ធបរិស័ទគ្រប់ជាន់ ដែលបានប្រតិបត្តិតាមសាសនិកវិធី ក្រោមអធិបតេយ្យនៃព្រះសម្មាសម្ពុទ្ធ ឲ្យបានប្រកបដោយសុខភាពអនាម័យដ៏បរិបូណ៌ សមតាមអធ្យាស្រ័យវត្ថុបំណងកុំបីឃ្លាតឡើយ !


Website: bvdcc.org

E-mail: chhenchhoun@gmail.com

YouTube: Vipassana Dhurak Buddhist Centre

YouTube: ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា

ទំនាក់ទំនង: ០៨៦ ៨ ៧៧៧ ៩៣ / ០៩៧ ៩៨០ ៥២ ៨២


សូមអរព្រះគុណ និងអរគុណ